UNITED NATIONS
OFFICE OF THE HIGH COMMISSIONER
FOR HUMAN RIGHTS IN CAMBODIA

NATIONS UNIES
BUREAU DU HAUT COMMISSAIRE
AUX DROITS DE L'HOMME AU CAMBODGE

អង្គការសហប្រជាជាតិ
ការិយាល័យនៃឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា

OHCHR

# សេចក្តីប្រកាសព័ត៌មាន

ភ្នំពេញ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨

ការិយាល័យឧត្តមស្នងការ អង្គការសហប្រជាជាតិ ទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា បានឃ្លាំមើលដំណើរការសវនាការថ្ងៃនេះ ដោយយកចិត្តទុកដាក់បំផុត ដែលធ្វើឡើងដោយតុលាការកំពូលលើករណីលោក ប៊ិន សំណាង និង លោក សុខ សំអឿន ។ ការិយាល័យឧត្តមស្នងការ សូមស្វាគមន៍ចំពោះសេចក្តីសម្រេចរបស់តុលាការកំពូល ដើម្បីដោះលែងជនជាប់ចោទទាំងពីរនាក់ឱ្យនៅក្រៅឃុំបណ្តោះអាសន្ន ហើយបង្វិលករណីនេះទៅសាលាឧទ្ធរណ៍ធ្វើការស៊ើបអង្កេតឡើងវិញ ។ ការិយាល័យឧត្តមស្នងការសង្ឃឹមថា ប្រការនេះនឹងជាឱកាសមួយដើម្បីធ្វើការពិនិត្យឡើងវិញនូវករណីនេះទាំងស្រុង និងឱ្យបានស៊ីជម្រៅទាំងផ្នែកអង្គហេតុ អង្គច្បាប់ និងនីតិវិធី ដើម្បីសម្រេចក្តីនេះអោយមានភាពយុត្តិធម៌ពិតប្រាកដ អនុលោមតាមច្បាប់ព្រហ្មទណ្ឌកម្ពុជា និងបទដ្ឋានអន្តរជាតិស្តីពីការជំនុំជំរះទោសដោយយុត្តិធម៌ ដូចមានចែងក្នុងរដ្ឋធម្មនុញ្ញ ដោយរាប់ទាំងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ។

ការិយាល័យឧត្តមស្នងការ អង្គការសហប្រជាជាតិ ទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជាសង្ឃឹមថា សេចក្តីសម្រេចនេះ នឹងបង្កើតបានជាបទដ្ឋានទាំងឡាយ សម្រាប់ដំណើរការក្តីព្រហ្មទណ្ឌ ដោយតុលាការកម្ពុជានាពេលអនាគត ។ សេចក្តីសម្រេចនេះបានធ្វើឡើង បន្ទាប់ពីដំណើរការក្តីអស់រយៈពេលជាច្រើនឆ្នាំដែលធ្វើអោយសៅហ្មង ចាប់តាំងពីការជំនុំជំរះឡើងវិញលើកដំបូង ដែលមានភាពមិនប្រក្រតីយ៉ាងច្រើន និងការរំលោភធ្ងន់ធ្ងរ ទៅលើសិទ្ធិនីតិវិធីរបស់ជនជាប់ចោទទាំងពីរ ។ សេចក្តីសម្រេចនេះបានទទួលការអបអរសាទរយ៉ាងកក់ក្តៅពីសាធារណជន រួមទាំងក្រុមគ្រួសាររបស់ជនជាប់ចោទ ដែលសមនឹងទទួលបានបែបនេះ យ៉ាងពិតប្រាកដ ។

No. 10, Street 302, Sangkat Boeng Keng Kang I, Khan Chamcar Mon, Phnom Penh Cambodia
Tel: +(855) 23 987 671 / 987 672 / 993 590 / 993 591 or 216 342  Fax: +(855) 23 212 579 or 213 587
E-mail: cambodia@ohchr.org  Website: http://cambodia.ohchr.org